**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០៥៤/១៧.....គ.ម.ក./ប្រ.ក

# ប្រកាស
# ស្តីពី
# ការបើកសាខារបស់ក្រុមហ៊ុនសមាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ការអនុញ្ញាតបើកសាខាក្រុមហ៊ុនសមភាគីកណ្តាល និងសាខាឈ្នួញជើងសាឧបករណ៍និស្សន្ទ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ÷

ក្រុមហ៊ុនដើម ÷ សំដៅដល់ក្រុមហ៊ុនសមភាគីកណ្តាល ឈ្នួញជើងសាឧបករណ៍និស្សន្ទ និងក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល និងឈ្នួញជើងសាឧបករណ៍និស្សន្ទ។

ច្បាប់ ÷ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

សាខា ÷ សំដៅដល់ទីកន្លែងផ្សេងពីទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនដើម សម្រាប់ធ្វើអាជីវកម្មក្នុងក្របខ័ណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតរបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

អនុក្រឹត្យ ÷ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

## ជំពូកទី ២
## ការអនុញ្ញាតបើកសាខា

### ប្រការ ៣.- ការអនុញ្ញាតបើកសាខាក្រុមហ៊ុនសមភាគីកណ្តាល និងសាខាឈ្នួញជើងសាឧបករណ៍និស្សន្ទ

គ្មានក្រុមហ៊ុនដើមណាមួយអាចបើកសាខាក្រុមហ៊ុនសមភាគីកណ្តាល និងសាខាឈ្នួញជើងសាឧបករណ៍និស្សន្ទ ឬគ្មានបុគ្គលណាមួយអាចតាំងខ្លួនជាសាខាក្រុមហ៊ុនសមភាគីកណ្តាល និងសាខាឈ្នួញជើងសាឧបករណ៍និស្សន្ទបានទេ លើកលែងតែក្រុមហ៊ុនដើម ឬបុគ្គលនោះទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

ការអនុញ្ញាតបើកសាខាមានសុពលភាពរយៈពេល ១ (មួយ) ឆ្នាំ។ ការបន្តការអនុញ្ញាតបើកសាខាមានសុពលភាពរយៈពេល ១ (មួយ) ឆ្នាំ គិតចាប់ពីការអនុញ្ញាតចាស់អស់សុពលភាព។

**ប្រការ ៤.- ការដាក់ពាក្យស្នើសុំការអនុញ្ញាតបើកសាខា**

ក្រុមហ៊ុនដើមដែលមានបំណងបើកសាខា និងបន្តការអនុញ្ញាតបើកសាខាក្រុមហ៊ុនសមភាគីកណ្ដាល និងសាខាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់បែបបទ និងឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។

ករណីស្នើសុំបន្តការអនុញ្ញាតបើកសាខា ក្រុមហ៊ុនដើមត្រូវដាក់ពាក្យស្នើសុំបន្តការអនុញ្ញាតបើកសាខាទៅតាមទម្រង់បែបបទ និងឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ គ.ម.ក. ក្នុងអំឡុងពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនពេលកាលបរិច្ឆេទដែលការអនុញ្ញាតចាស់អស់សុពលភាព។ ការដាក់ពាក្យស្នើសុំបន្តការអនុញ្ញាតបើកសាខានៅក្រោយកាលបរិច្ឆេទដែលការអនុញ្ញាតចាស់អស់សុពលភាព ត្រូវបានចាត់ទុកជាការដាក់ពាក្យស្នើសុំថ្មី។

អគ្គនាយកនៃ **គ.ម.ក** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីសេចក្ដីយល់ព្រម ឬបដិសេធលើពាក្យស្នើសុំការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល គ.ម.ក. ទទួលបានឯកសារពេញលេញ។

ការអនុញ្ញាតបើកសាខាត្រូវអស់សុពលភាពជាស្វ័យប្រវត្តិក្នុងករណីអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្ដាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុនដើមអស់សុពលភាព ឬត្រូវបានដកហូត។

**ប្រការ ៥.- លក្ខខណ្ឌតម្រូវចំពោះការអនុញ្ញាតបើកសាខា**

ក្រុមហ៊ុនដើមដែលស្នើសុំការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១. ចុះបញ្ជីសាខាក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។

២. ចុះបញ្ជីពន្ធដារសម្រាប់សាខាអនុលោមតាមច្បាប់ស្ដីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣. មានរចនាសម្ព័ន្ធគ្រប់គ្រងសាខាដែលកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ចដែលអាចធានាបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងអភិបាលកិច្ចសាជីវកម្មល្អ។

៤. មានទីតាំងសាខាសមស្រប និងមានបំពាក់បរិក្ខារគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្ម។

៥. មានហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់សម្រាប់សាខា។

៦. មានប្រព័ន្ធ និងគោលនយោបាយគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងសមស្រប។

៧. ធានាឱ្យបាននូវនីតិវិធីសមស្របក្នុងការដោះស្រាយការតវ៉ារបស់អតិថិជន និងវិវាទរវាងបុគ្គលិកនិងអតិថិជន។

៨. មានធនធានមនុស្សដូចខាងក្រោម÷

ក. មាននាយកគ្រប់គ្រងសាខា ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក** និងបំពេញលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃប្រការ ៧ នៃប្រកាសស្ដីពីការផ្ដល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ ចំពោះសាខាក្រុមហ៊ុនសមភាគីកណ្ដាល។

៨. ត្រូវមាននាយកគ្រប់គ្រងសាខាដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ គ.ម.ក និងបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ១ នៃប្រការ ២០ នៃប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ និងមានភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ គ.ម.ក. ចំពោះសាខាឈ្មួញជើងសាឧបករណ៍និស្សន្ទ។

៩. មិនស្ថិតនៅក្រោមករណីណាមួយដូចមានចែងក្នុងចំណុចទី ១៣ ប្រការ ៥ នៃប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ។

១០. លក្ខខណ្ឌផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ គ.ម.ក.។

## ប្រការ ៦.- ទម្រង់បែបបទ និងឯកសារភ្ជាប់

ក្រុមហ៊ុនដើម ត្រូវបំពេញបែបបទទៅតាមទម្រង់ដែលបានកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។ ឯកសារភ្ជាប់នៃទម្រង់ពាក្យស្នើសុំអាចមានជាអាទិ៍ដូចខាងក្រោម÷

១. លិខិតទទួលចុះបញ្ជីបង្កើតសាខាចេញដោយក្រសួងពាណិជ្ជកម្ម។

២. លិខិតបញ្ជាក់សាខាសហគ្រាស និងប័ណ្ណពន្ធប៉ាតង់សាខាសហគ្រាសថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣. កំណត់ហេតុប្រជុំភាគហ៊ុនិក ឬស្ថាបនិក ឬក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការស្នើសុំការអនុញ្ញាតបើកសាខា/បន្តការអនុញ្ញាតបើកសាខា។

៤. ឯកសារបញ្ជាក់ពីសិទ្ធិប្រើប្រាស់ទីតាំង ឬបរិវេណសាខា។

៥. គោលនយោបាយនិងយន្តការត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ។

៦. ឯកសារផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។

## ប្រការ ៧.- ឯកសារបន្ថែម

អគ្គនាយកនៃ គ.ម.ក. អាចតម្រូវឱ្យក្រុមហ៊ុនដើមដែលដាក់ពាក្យស្នើសុំការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខា ផ្តល់ឯកសារបន្ថែម និងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដើម្បីធានាថាការដាក់ពាក្យស្នើសុំនេះ បំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

## ប្រការ ៨.- ការចុះត្រួតពិនិត្យដល់ទីកន្លែង

អគ្គនាយកនៃ គ.ម.ក ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខា និងដើម្បីធ្វើការត្រួតពិនិត្យនូវរាល់ព័ត៌មាន ទិន្នន័យ ឯកសារ និងប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្មនៅសាខានោះ។

## ប្រការ ៩.- ការចាប់ផ្តើមអាជីវកម្ម

ក្រុមហ៊ុនដើមត្រូវចាប់ផ្តើមធ្វើអាជីវកម្មនៅសាខាដែលទទួលបានការអនុញ្ញាតក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទផ្តល់ការអនុញ្ញាតបើកសាខាពីអគ្គនាយកនៃ គ.ម.ក.។

**ប្រការ ១០.- ការតព្វកិច្ចស្នើសុំការអនុញ្ញាតលើការផ្លាស់ប្តូរ ឬតែងតាំង**

ក្រុមហ៊ុនដើមត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ គ.ម.ក. ក្នុងករណីណាមួយដូចខាងក្រោម÷

១. ផ្លាស់ប្តូរ ឬតែងតាំងនាយកគ្រប់គ្រងសាខា។

២. ផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីសាខា។

៣. ផ្លាស់ប្តូរភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ រវាងក្រុមហ៊ុនដើមនិងសាខា ឬរវាងសាខានិងសាខា។

ប្រសិនបើតំណែងនាយកគ្រប់គ្រងសាខានៅទំនេរ ក្រុមហ៊ុនដើមត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

ប្រសិនបើតំណែងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទក្នុងសាខានៅទំនេរ ក្រុមហ៊ុនដើមត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

**ប្រការ ១១.- របាំងព័ត៌មាន**

ក្រុមហ៊ុនដើមត្រូវធានាថា សាខាក្រុមហ៊ុនសមភាគីកណ្តាល និងសាខាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវធ្វើអាជីវកម្មដាច់ដោយឡែកពីគ្នា និងដាច់ដោយឡែកពីអាជីវកម្មផ្សេងទៀតដែលខ្លួនមាន ដោយត្រូវមាន បរិក្ខារ ប្រព័ន្ធព័ត៌មានវិទ្យា ធនធានមនុស្សដាច់ដោយឡែកពីគ្នា និងត្រូវមានរបាំងព័ត៌មានសមស្របនៅក្នុងសាខានោះ។

**ប្រការ ១២.- ការព្យួរ ឬការលុបចោលការអនុញ្ញាតបើកសាខា**

អគ្គនាយកនៃ គ.ម.ក. អាចព្យួរ ឬលុបចោលការអនុញ្ញាតបើកសាខាក្រុមហ៊ុនសមភាគីកណ្តាល និងសាខាឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្នុងករណីក្រុមហ៊ុនដើមស្នើសុំផ្អាក ឬឈប់ធ្វើប្រតិបត្តិការអាជីវកម្ម ឬស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១. មិនអនុវត្តសេចក្តីសម្រេចដែលត្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុង។

២. កំពុងស្ថិតក្នុងស្ថានភាពបច្ចេកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការទៅតាមមូលហេតុស្របច្បាប់។

៣. មិនអាចបន្តគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ។

**ប្រការ ១៣.- ការបិទសាខា**

ក្រុមហ៊ុនដើមដែលមានបំណងបិទសាខាក្រុមហ៊ុនសមភាគីកណ្តាល និង/ឬសាខាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវស្នើសុំការអនុញ្ញាតជាមុន និងត្រូវបំពេញលក្ខខណ្ឌតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៣
## កម្រៃ

**ប្រការ ១៤.- ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃការអនុញ្ញាត**

ក្រុមហ៊ុនដើមដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខាទៅតាមកម្រៃដូចខាងក្រោម÷

១. ចំពោះការស្នើសុំការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខាក្រុមហ៊ុនសមភាគីកណ្ដាល

- ថ្លៃពាក្យស្នើសុំការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខាចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់

- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល

- ថ្លៃការអនុញ្ញាតជាសាច់ប្រាក់ចំនួន ១.៦០០.០០០ (មួយលានប្រាំមួយរយពាន់) រៀល សម្រាប់រយៈពេលមួយឆ្នាំ ក្នុងមួយសាខា។

២. ចំពោះការស្នើសុំការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខាឈ្មួញជើងសាឧបករណ៍និស្សន្ទ

- ថ្លៃពាក្យស្នើសុំការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខាចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់

- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៤០០.០០០ (បួនរយពាន់) រៀល

- ថ្លៃការអនុញ្ញាតជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់រយៈពេលមួយឆ្នាំ ក្នុងមួយសាខា។

៣. ចំពោះការស្នើសុំដូចខាងក្រោម÷

- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២០០.០០០ (ពីររយពាន់) រៀល សម្រាប់ការផ្លាស់ប្ដូរទីស្នាក់ការនីមួយៗ

- ថ្លៃពាក្យស្នើសុំជាសាច់ប្រាក់ចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ៦០.០០០ (ហុកសិបពាន់) រៀល សម្រាប់ការស្នើសុំផ្លាស់ប្ដូរ ឬតែងតាំងនាយកគ្រប់គ្រងសាខា

- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២០.០០០ (ម្ភៃពាន់) រៀល សម្រាប់ការផ្លាស់ប្ដូរទីតាំងបំពេញការងាររបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ រវាងក្រុមហ៊ុនដើម និងសាខា ឬរវាងសាខា និងសាខា។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រកាសនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីការស្នើសុំការអនុញ្ញាតបើកសាខា ឬការបន្តការអនុញ្ញាតបើកសាខា ការស្នើសុំផ្លាស់ប្ដូរទីស្នាក់ការចុះបញ្ជីសាខា ការស្នើសុំផ្លាស់ប្ដូរ ឬតែងតាំងនាយកគ្រប់គ្រងសាខា និងការស្នើសុំផ្លាស់ប្ដូរទីតាំងបំពេញការងាររបស់ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៤

## បទប្បញ្ញត្តិផ្សេងៗ

### ប្រការ ១៥.- ការទទួលខុសត្រូវ

ក្រុមហ៊ុនដើមត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងត្រូវទទួលខុសត្រូវលើកាតព្វកិច្ច និងរាល់សកម្មភាពរបស់សាខា។

### ប្រការ ១៦.- ការផ្លាស់ប្ដូរ ឬកែប្រែព័ត៌មាន

ក្រុមហ៊ុនដើមត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក គ.ម.ក. ក្នុងករណីមានការកែប្រែឯកសារ ឬព័ត៌មានពាក់ព័ន្ធនឹងពាក្យស្នើសុំការអនុញ្ញាតបើកសាខា ឬបន្តការអនុញ្ញាតបើកសាខា។

**ប្រការ ១៧.- ភារកិច្ចផ្ដល់របាយការណ៍**

ក្រុមហ៊ុនដើមត្រូវបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មសាខានៅក្នុងរបាយការណ៍សាមាយិក និងរបាយការណ៍ផ្សេងទៀតដែលត្រូវដាក់ជូនមក គ.ម.ក. អនុលោមតាមប្រការ ៣២ នៃប្រកាសស្ដីពីការផ្ដល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ។

**ប្រការ ១៨.- ការផ្លាស់ប្ដូរ ឬកែប្រែព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការអនុញ្ញាត**

បន្ទាប់ពីទទួលបានការអនុញ្ញាត/បន្តការអនុញ្ញាតបើកសាខាពីអគ្គនាយកនៃ គ.ម.ក. ក្រុមហ៊ុនដើមត្រូវបន្តគោរពតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៥ និងត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ គ.ម.ក. មុននឹងធ្វើការផ្លាស់ប្ដូរ ឬកែប្រែព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការអនុញ្ញាតអនុលោមតាមប្រកាសនេះ។

**ប្រការ ១៩.- ការចូលរួមវគ្គបណ្ដុះបណ្ដាលបន្ត**

មុននឹងលទ្ធផលនៃការចូលរួមវគ្គបណ្ដុះបណ្ដាល ឬការប្រឡងរៀបចំដោយ គ.ម.ក. អស់សុពលភាព នាយកគ្រប់គ្រងសាខា ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ គ.ម.ក. ត្រូវចូលរួមវគ្គ-បណ្ដុះបណ្ដាលបន្តរៀបចំដោយ គ.ម.ក. ឬដោយស្ថាប័នបណ្ដុះបណ្ដាលដែលទទួលបានសិទ្ធិពី គ.ម.ក. លើកលែងតែមានការកំណត់ដោយឡែកតាមស្ថានភាពជាក់ស្ដែងដោយអគ្គនាយកនៃ គ.ម.ក.។

**ប្រការ ២០.- ការបើកការិយាល័យតំណាង**

ក្រុមហ៊ុនដើមដែលមានបំណងបើកការិយាល័យតំណាង ត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ គ.ម.ក. និងត្រូវអនុវត្តតាមសៀវភៅបន្ទុកដាច់ដោយឡែកដែលកំណត់ដោយ គ.ម.ក.។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**ប្រការ ២១.- ការស្នើសុំបន្តការអនុញ្ញាតបើកសាខាយឺតយ៉ាវ**

ក្រុមហ៊ុនដើមដែលដាក់ពាក្យស្នើសុំបន្តការអនុញ្ញាតបើកសាខាពី គ.ម.ក. តិចជាង ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលការអនុញ្ញាតចាស់អស់សុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពី គ.ម.ក. ជាសាច់ប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល ក្នុង ១ (មួយ) ថ្ងៃ ចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវ។

**ប្រការ ២២.- ពិន័យអន្តរការណ៍**

ដោយមិនគិតពីទោសទណ្ឌផ្សេងទៀត ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាននៅព្រះរាជាណាចក្រកម្ពុជា អគ្គនាយកនៃ គ.ម.ក. អាចដាក់ពិន័យអន្តរការណ៍ជាសាច់ប្រាក់ដូចខាងក្រោម÷

១. មិនលើសពី ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះនាយកគ្រប់គ្រងសាខាដែលប្រព្រឹត្តល្មើសនឹងចំណុចទី៨ ប្រការ ៥ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ គ.ម.ក.។

២. មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល ចំពោះក្រុមហ៊ុនដើមដែលប្រព្រឹត្តល្មើសនឹងប្រការ ១០ ប្រការ ១១ ប្រការ ១៣ ប្រការ ១៥ ប្រការ ១៧ និងប្រការ ១៨ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ គ.ម.ក.។

## ប្រការ ២៣.- ទណ្ឌកម្មរដ្ឋបាល

ករណីក្រុមហ៊ុនដើម ឬនាយកគ្រប់គ្រងសាខា បានប្រព្រឹត្តល្មើសនឹងចំណុចទី៨ ប្រការ ៥ ប្រការ ១០ ប្រការ ១១ ប្រការ ១៣ ប្រការ ១៥ ប្រការ ១៧ ប្រការ ១៨ នៃប្រកាសនេះ និងការណែនាំរបស់អគ្គនាយកនៃ គ.ម.ក. អគ្គនាយកនៃ គ.ម.ក. មានសិទ្ធិចាត់វិធានការណ៍ពិន័យអន្តរការណ៍ ដូចមានចែងក្នុងប្រការ ២២ នៃប្រកាសនេះ និង/ឬទណ្ឌកម្មរដ្ឋបាលណាមួយដូចខាងក្រោម ÷

១. ព្រមាន។

២. ដឹកនាំកែតម្រង់។

៣. ដាក់កំហិតលើការអនុញ្ញាត។

៤. ព្យួរការអនុញ្ញាត។

៥. ដកហូតការអនុញ្ញាត។

# ជំពូកទី ៦
# អវសានប្បញ្ញត្តិ

## ប្រការ ២៤.- គោលការណ៍ណែនាំផ្សេងៗ

អគ្គនាយកនៃ គ.ម.ក. អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

## ប្រការ ២៥.- ការអនុវត្ត

អគ្គនាយកនៃ គ.ម.ក. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋាន-អង្គភាពដទៃទៀតដែលចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៩ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៥
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ